Australian Government
Services Australia

KHMER

# តើជម្រើសរបស់អ្នកមានអ្វីខ្លះ ប្រសិនបើអ្នកមិនយល់ស្រប ជាមួយនឹងសេចក្តីសម្រេច?

ប្រសិនបើអ្នកមិនយល់ ឬមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចដែលយើងបានធ្វើ អ្នកអាចស្នើសុំការពន្យល់ ឬដាក់ពាក្យសុំសម្រាប់ការពិនិត្យឡើងវិញជាផ្លូវការ។

## ការពន្យល់នៃសេចក្តីសម្រេច

អ្នកអាចស្នើសុំយើងឱ្យពន្យល់អំពីសេចក្តីសម្រេចរបស់យើង។ អ្នកប្រហែលជាចង់ស្នើសុំសម្រាប់ការពន្យល់ ប្រសិនបើអ្នកមិនយល់សេចក្តីសម្រេចដែលយើងបានធ្វើ។

អ្នកអាចធ្វើដូចនេះ នៅពេលណាក៏បាន។

សមាជិកបុគ្គលិកដែលមានបទពិសោធន៍នឹងទាក់ទងអ្នក ដើម្បីពន្យល់ពីសេចក្តីសម្រេច និងឆ្លើយសំណួរណាមួយដែលអ្នកមាន។ យើងប្រហែលជាអាចចាត់ចែងលើកំហុសរបស់អ្នក ឬផ្លាស់ប្តូរសេចក្តីសម្រេច ដោយមិនចាំបាច់ត្រូវការការពិនិត្យសើរើឡើងវិញជាផ្លូវការ។

នៅពេលអ្នកស្នើសុំការពន្យល់ យើងមានគោលបំណងទាក់ទងអ្នកនៅក្នុងរយៈពេល 14 ថ្ងៃ។

អ្នកមិនត្រូវការបង់ប្រាក់សម្រាប់ការពន្យល់អំពីសេចក្តីសម្រេចទេ។

## ការពិនិត្យសើរើឡើងវិញជាផ្លូវការ

អ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៃសេចក្តីសម្រេចរបស់យើងបាន។ អ្នកប្រហែលជាចង់ដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ ប្រសិនបើអ្នកយល់សេចក្តីសម្រេចរបស់យើង ប៉ុន្តែមិនយល់ព្រមជាមួយនឹងសេចក្តីសម្រេចនេះ។

អ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ នៅពេលណាក៏បាន។ អ្នកមិនចាំបាច់ត្រូវស្នើសុំការពន្យល់ជាមុនទេ។

នៅពេលអ្នកដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ, Authorised Review Officer របស់យើងនឹង៖

- មានគោលបំណងបញ្ចប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 49 ថ្ងៃ
- ពិនិត្យមើលអង្គហេតុ ច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនឹងសេចក្តីសម្រេច
- ផ្លាស់ប្តូរសេចក្តីសម្រេច ប្រសិនបើវាខុស
- សរសេរទៅប្រាប់អ្នកឱ្យដឹងអំពីលទ្ធផលនៃការពិនិត្យសើរើឡើងវិញជាផ្លូវការរបស់អ្នក។

អ្នកមិនត្រូវការបង់ប្រាក់សម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៃសេចក្តីសម្រេចទេ។

## របៀបដើម្បីស្នើសុំការពន្យល់ ឬការពិនិត្យសើរើឡើងវិញជាផ្លូវការ

អ្នកអាចស្នើការពន្យល់ ឬដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ ដោយប្រើជម្រើសណាមួយដូចខាងក្រោម៖

- ហៅទូរសព្ទទៅខ្សែទូរសព្ទបង់ប្រាក់ Centrelink ធម្មតា
- ហៅទូរសព្ទមកយើងតាមលេខ **131 202** ដើម្បីនិយាយជាមួយអ្នកណាម្នាក់ជាភាសារបស់អ្នក
- ចូលទៅទស្សនា មជ្ឈមណ្ឌលសេវាកម្ម។

អ្នកក៏អាចបំពេញទម្រង់បែបបទនៃ *Explanation or formal review of a decision* (*ការពន្យល់ ឬការពិនិត្យសើរើឡើងវិញជាផ្លូវការនៃសេចក្តីសម្រេច*)និងផ្តល់ឱ្យយើងនូវឯកសារគាំទ្រតាមអនឡាញ ដោយប្រើមធ្យោបាយណាមួយតាម៖

- គណនីអនឡាញ Centrelink របស់អ្នក តាមរយៈ myGov

- កម្មវិធីឧបករណ៍ចល័ត Express Plus Centrelink។

ទៅកាន់ **servicesaustralia.gov.au/ss351** ដើម្បីទាញយកទម្រង់បែបបទនៃ *Explanation or formal review of a decision (ការពន្យល់ ឬការពិនិត្យសើរើឡើងវិញជាផ្លូវការនៃសេចក្តីសម្រេច)*។

ប្រសិនបើអ្នកមិនអាចផ្តល់ឯកសារមកឱ្យយើងតាមអនឡាញបានទេ អ្នកអាចផ្ញើវាតាមប្រៃសណីយ៍ទៅ៖

**Centrelink**
**Reply Paid 7800**
**Canberra BC ACT 2610**

សម្រាប់សេចក្តីសម្រេចអំពី Assistance for Isolated Children អ្នកត្រូវការបំពេញនៅក្នុងទម្រង់បែបបទមួយផ្សេង។ នេះគឺជា *ABSTUDY and Assistance for Isolated Children (AIC) Explanation or formal review of a decision form (ទម្រង់បែបបទនៃការពន្យល់ ឬការពិនិត្យសើរើឡើងវិញជាផ្លូវការទាក់ទងនឹង ABSTUDY និង Assistance for Isolated Children (AIC))។ អ្នកអាចបញ្ជូនវាត្រឡប់មកឱ្យយើងវិញដោយប្រើព័ត៌មានលម្អិតដែលមាននៅលើទម្រង់បែបបទ។*

ទៅកាន់ **servicesaustralia.gov.au/sy054** ដើម្បីទទួលបាន *ABSTUDY and Assistance for Isolated Children (AIC) Explanation or formal review of a decision form (ទម្រង់បែបបទនៃការពន្យល់ ឬការពិនិត្យសើរើឡើងវិញជាផ្លូវការទាក់ទងនឹង ABSTUDY និង Assistance for Isolated Children (AIC))*។

## ប្រសិនបើអ្នកមិនយល់ព្រមជាមួយបំណុល Centrelink

ជាទូទៅអ្នកអាចស្នើសុំការពន្យល់ ឬដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៃបំណុលរបស់អ្នកនៅពេលណាក៏បាន។ បំណុលខ្លះមានការកម្រិតពេលកំណត់ខុសគ្នាសម្រាប់អ្នក ដើម្បីដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ។ អ្នកអាចអានបន្ថែមស្តីពីការកម្រិតពេលកំណត់ខាងក្រោម។

| **ប្រភេទនៃការបង់ប្រាក់** | **ការកម្រិតពេលកំណត់នៃការពិនិត្យសើរើឡើងវិញជាផ្លូវការ** |
|---|---|
| Assistance for Isolated Children | អ្នកត្រូវតែដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 3 ខែ ចាប់ពីពេលបរិច្ឆេទដែលយើងបានធ្វើសេចក្តីសម្រេចរបស់យើង។ |
| Tertiary Access Payment | អ្នកត្រូវតែដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 13 សប្តាហ៍ ចាប់ពីពេលដែលយើងប្រាប់អ្នកអំពីសេចក្តីសម្រេច។ |

ប្រសិនបើអ្នកមានបំណុល អ្នកអាចស្នើសុំយើងឱ្យផ្អាកការបង់ប្រាក់សងវិញរបស់អ្នក រហូតដល់ការពន្យល់ ឬការពិនិត្យសើរើឡើងវិញជាផ្លូវការរបស់បានត្រូវបញ្ចប់។ អ្នកអាចធ្វើដូចនេះបាន នៅពេលអ្នកនិយាយជាមួយយើងអំពីសេចក្តីសម្រេច។

## ការកម្រិតពេលកំណត់នៅពេលដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ

អ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 13 សប្តាហ៍ ចាប់ពីកាលបរិច្ឆេទដែលយើងប្រាប់អ្នកអំពីសេចក្តីសម្រេច។

ការបង់ប្រាក់ខ្លះមានការកម្រិតពេលកំណត់ខុសគ្នាសម្រាប់អ្នកដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ។ ការនេះអនុវត្តទាំងចំពោះការទាមទារ និងសេចក្តីសម្រេចអំពីសិទ្ធិទទួលបាន។

អ្នកនៅតែអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការ ក្រោយការកម្រិតពេលកំណត់នៃការពិនិត្យសើរើការបង់ប្រាក់របស់អ្នកឡើងវិញ។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើសេចក្តីសម្រេចត្រូវបានផ្លាស់ប្តូរ អ្នកប្រហែលជាអាចទទួលបានការបង់ប្រាក់របស់អ្នកតែចាប់ពីកាលបរិច្ឆេទដែលអ្នកដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការប៉ុណ្ណោះ។

អ្នកអាចអានបន្ថែមស្តីពីការកម្រិតពេលកំណត់ខាងក្រោម។

| ប្រភេទនៃការបង់ប្រាក់ | ការកម្រិតពេលកំណត់នៃការពិនិត្យសើរើឡើងវិញជាផ្លូវការ |
|---|---|
| Family Tax Benefit | អ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 52 សប្តាហ៍ ចាប់ពីកាលបរិច្ឆេទដែលយើងប្រាប់អ្នកអំពីសេចក្តីសម្រេច។ |
| Family Tax Benefit and Child Support | អ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 52 សប្តាហ៍ ចាប់ពីកាលបរិច្ឆេទដែលយើងប្រាប់អ្នកអំពីសេចក្តីសម្រេច។<br>ប្រសិនបើអ្នកក៏ជាអតិថិជន Child Support ផងដែរ ហើយសេចក្តីសម្រេចប៉ះពាល់ដល់ការវាយតម្លៃការគាំទ្រកូនរបស់អ្នក នោះអ្នកគួរដាក់ពាក្យសុំសម្រាប់ការពិនិត្យ សើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 28 ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែល យើងប្រាប់អ្នកអំពីសេចក្តីសម្រេច។ |
| Child Care Subsidy | អ្នកគួរដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 13 សប្តាហ៍ ចាប់ពីកាលបរិច្ឆេទដែលយើងប្រាប់អ្នកអំពីសេចក្តីសម្រេច។ |
| Parental Leave Pay | អ្នកគួរដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 28 ថ្ងៃ ចាប់ពីថ្ងៃយើងធ្វើសេចក្តីសម្រេច។ |
| Dad and Partner Pay | អ្នកគួរដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 28 ថ្ងៃ ចាប់ពីថ្ងៃយើងធ្វើសេចក្តីសម្រេច។ |
| Tertiary Access Payments | អ្នកត្រូវតែដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 13 សប្តាហ៍ ចាប់ពីពេលដែលយើងប្រាប់អ្នកអំពីសេចក្តីសម្រេច។ |
| Assistance for Isolated Children Scheme | អ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅពេលណាក៏បាន។<br>ប្រសិនបើសេចក្តីសម្រេចគឺស្តីពីការស្តារឡើងនៃបំណុល នោះអ្នកត្រូវតែដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញជាផ្លូវការនៅក្នុងរយៈពេល 3 ខែ ចាប់ពីកាលបរិច្ឆេទដែលយើងធ្វើសេចក្តីសម្រេច។ |

## ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងលទ្ធផលនៃការពិនិត្យសើរើឡើងវិញជាផ្លូវការ

ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងលទ្ធផលនៃការពិនិត្យសើរើឡើងវិញជាផ្លូវការនៃសេចក្តីសម្រេចរបស់ Centrelink នោះអ្នកអាចស្នើសុំ Administrative Review Tribunal (ART) (សាលាជម្រះក្តីឧទ្ធរណ៍រដ្ឋបាល (ART)) ដើម្បីពិនិត្យសើរើវាឡើងវិញបាន។ ART គឺជាសាលាជម្រះក្តីឯករាជ្យមួយ។

ART មាន 2 កម្រិតនៃការពិនិត្យសើរើឡើងវិញ។ នេះមានន័យថា ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងការពិនិត្យសើរើឡើងវិញលើកទីមួយរបស់ ART នោះអ្នកអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញលើកទីពីរបាន។

ប្រសិនបើអ្នកកំពុងដាក:ពាក្យសុំទៅ ART , អ្នកអាចស្នើសុំឱ្យយើងផ្អាកការបង់សងបំណុលរបស់អ្នកឡើងវិញបាន រហូតដល់ការពិនិត្យសើរើឡើងវិញលើកទីមួយរបស់ ART ត្រូវបានបញ្ចប់។

អាចមានដំណើរការពិនិត្យសើរើឡើងវិញ និងដំណើរការបណ្តឹងឧទ្ធរណ៍ខុសគ្នា ប្រសិនបើសេចក្តីសម្រេចទាក់ទងនឹងការបង់ប្រាក់ដូចខាងក្រោម៖

- Assistance for Isolated Children
- Rural ex-gratia payment.

## នៅពេលដាក់ពាក្យទៅ ART

អ្នកគួរតែដាក់ពាក្យសុំនៅក្នុងរយៈពេល 13 សប្តាហ៍ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចក្នុងការពិនិត្យសើរើឡើងវិញជាផ្លូវការរបស់យើង។ អ្នកនៅតែអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញ ART ក្រោយរយៈពេល 13 សប្តាហ៍។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើ ART ផ្លាស់ប្តូរសេចក្តីសម្រេច នោះអ្នកប្រហែលជាអាចទទួលបានការបង់ប្រាក់របស់អ្នកតែចាប់ពីកាលបរិច្ឆេទដែលអ្នកបានដាក់ពាក្យសម្រាប់ការពិនិត្យសើរើឡើងវិញប៉ុណ្ណោះ។

ប្រសិនបើអ្នកចង់បានការពិនិត្យសើរើឡើងវិញនៃសេចក្ដីសម្រេចអំពី Paid Parental Leave Scheme, នោះអ្នកគួរតែដាក់ពាក្យសុំនៅក្នុងរយៈពេល 28 ថ្ងៃ នៃសេចក្ដីសម្រេចការពិនិត្យសើរើឡើងវិញជាផ្លូវការរបស់យើង។

## របៀបដាក់ពាក្យទៅ ART

ដើម្បីដាក់ពាក្យសម្រាប់ការពិនិត្យសើរើឡើងវិញនៃសេចក្ដីសម្រេច ART, សូមទៅកាន់ **art.gov.au** និងធ្វើតាមការណែនាំរបស់ពួកគេ។

ក្រោយពីអ្នកដាក់បញ្ជូនការដាក់ពាក្យសុំហើយ យើងនឹងផ្ញើសេចក្ដីថ្លែង ART។ វាមានហេតុផលមួយចំនួនសម្រាប់សេចក្ដីសម្រេច និងឯកសារទីភ្នាក់ងារដែលពាក់ព័ន្ធមួយចំនួន។ អ្នកក៏នឹងត្រូវទទួលបានច្បាប់ចម្លងនៃសេចក្ដីថ្លែងរបស់យើងមួយច្បាប់ និងឯកសារនានាផងដែរ។

ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងការពិនិត្យសើរើឡើងវិញលើកទីមួយរបស់ ART, អ្នកប្រហែលជាអាចដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញ ART លើកទីពីរបាន។ អ្នកគួរធ្វើការដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើឡើងវិញ ART លើកទីពីរ នៅក្នុងរយៈពេល 28 ថ្ងៃនៃការទទួលសេចក្ដីសម្រេចនៃការពិនិត្យសើរើឡើងវិញលើកទីមួយ។

## តើមានថ្លៃចំណាយអ្វីខ្លះ?

សម្រាប់ប្រភេទនៃសេចក្ដីសម្រេចខ្លះ អាចមានថ្លៃឈ្នួលដាក់ពាក្យសុំ ART។

យើងមិនអាចជួយអ្នកជាមួយនឹងចំណាយក្នុងការដាក់ពាក្យសុំសម្រាប់ការពិនិត្យសើរើសឡើងវិញរបស់ ART បានទេ។ ART ក៏មិនអាចផ្ដល់ជារង្វាន់ដល់អ្នកសម្រាប់ចំណាយនានាបានផងដែរ ប្រសិនបើអ្នកបានជោគជ័យ។

ប្រសិនបើការពិនិត្យសើរើសឡើងវិញរបស់អ្នកជាមួយ ART មិនបានជោគជ័យ យើងមិនស្នើឱ្យអ្នកបង់ចំណាយរបស់យើងទេ។

# តើមានអ្វីទៀតដែលអ្នកគួរដឹង

## ជំនួយផ្លូវច្បាប់

អ្នកអាចជ្រើសរើសដើម្បីមានអ្នកតំណាងផ្លូវច្បាប់ផ្ទាល់ខ្លួន ប្រសិនបើអ្នកស្វែងរកការពិនិត្យសើរើជាផ្លូវការនៃសេចក្ដីសម្រេច។

ជំនួយ និងដំបូន្មានឥតគិតថ្លៃអាចរកបានពី៖

- គេហទំព័រ Economic Justice Australia (យុត្តិធម៌សេដ្ឋកិច្ចអូស្ត្រាលី) – **ejaustralia.org.au**
- គេហទំព័រ National Legal Aid (ជំនួយផ្លូវច្បាប់ថ្នាក់ជាតិ) – **nationallegalaid.org**

## ការទាមទារសំណង

នៅក្នុងករណីខ្លះ អ្នកប្រហែលជាអាចទាមទារសំណង ប្រសិនបើអ្នកគិតថាយើងបានធ្វើកំហុសដែលបានបណ្ដាលឱ្យអ្នកមានការបាត់បង់ផ្នែកហិរញ្ញវត្ថុ ឬគ្រោះថ្នាក់ដទៃទៀត។

អ្នកគួរតែស្វែងរកជម្រើសនៃការពិនិត្យសើរើឡើងវិញទាំងអស់របស់អ្នក នៅមុនពេលអ្នកទាមទារសំណង។ យើងអាចមិនសងសំណងអ្នក ប្រសិនបើជម្រើសដទៃទៀតអាចដោះស្រាយបញ្ហាបាន។

អ្នកអាចទាមទារសំណង ដោយបំពេញ *Compensation Application* form *(ទម្រង់បែបបទការដាក់ពាក្យសុំសំណង)*។ ប្រសិនបើអ្នកមិនអាចបោះពុម្ពវាបាន អ្នកអាចសួរបុគ្គលិកនៅមជ្ឈមណ្ឌលសេវាកម្មនៅតាមតំបន់របស់អ្នក ដើម្បីបោះពុម្ពទម្រង់បែបបទ។ អ្នកក៏អាចហៅទូរសព្ទមកយើងតាមខ្សែទូរសព្ទបង់ប្រាក់ Centrelink ធម្មតារបស់អ្នក ឬតាមលេខ **131 202** ហើយយើងអាចផ្ញើវាទៅឱ្យអ្នកបាន។ នៅពេលហៅទូរសព្ទទៅខ្សែទូរសព្ទបង់ប្រាក់របស់អ្នក សូមប្រាប់យើងឱ្យដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងចាត់ចែងឱ្យមានអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ។

ទៅកាន់ **servicesaustralia.gov.au/ss509** ដើម្បីទាញយក *Compensation Application form (ទម្រង់បែបបទដាក់ពាក្យសុំសំណង)*។

# សម្រាប់ព័ត៌មានបន្ថែម

- ទៅកាន់ **servicesaustralia.gov.au/reviewsandappeals** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- ទៅកាន់ **servicesaustralia.gov.au/yourlanguage** ជាកន្លែងដែលអ្នកអាចអាន ស្ដាប់ ឬមើលព័ត៌មានជាភាសារបស់អ្នកបាន
- សូមហៅទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពីការបង់ប្រាក់ និងសេវាកម្ម Centrelink
- សូមហៅទូរសព្ទទៅលេខ **132 011** សម្រាប់ Medicare និងលេខ **131 272** សម្រាប់ Child Support។ សូមប្រាប់ឱ្យយើងដឹងប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងចាត់ចែងឱ្យមានអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ
- ចូលទៅទស្សនាមជ្ឈមណ្ឌលសេវាកម្ម។

ចំណាំ៖ ការហៅទូរសព្ទពីទូរសព្ទផ្ទះរបស់អ្នកទៅ ‘13’ លេខពីកន្លែងណាមួយនៅក្នុងប្រទេសអូស្ត្រាលី គឺត្រូវបានគិតថ្លៃតាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទតាមតំបន់ ហើយក៏អាចប្រែប្រួលផងដែរក្នុងចំណោមអ្នកផ្ដល់សេវាទូរសព្ទនានា។ ហៅទូរសព្ទទៅលេខ ‘1800’ ពីទូរសព្ទផ្ទះរបស់អ្នកគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងពីទូរសព្ទចល័ត អាចត្រូវបានកំណត់ម៉ោង ព្រមទាំងត្រូវបានគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នាចង់ដាក់ពាក្យដើម្បីទទួលបានការបង់ប្រាក់ និងដើម្បីធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេសរបស់អ្នក។

# What are your options if you do not agree with a decision?

If you do not understand or agree with a decision we have made, you can ask for an explanation or apply for a formal review.

## Explanation of decision

You can ask us to explain our decision. You may want to ask for an explanation if you do not understand a decision we have made.

You can do this at any time.

An experienced staff member will contact you to explain the decision and answer any questions you have. We might be able to sort out your concerns or change the decision without needing a formal review.

When you ask for an explanation, we aim to contact you within 14 days.

You do not have to pay for an explanation of a decision.

## Formal review

You can apply for a formal review of our decision. You may want to apply for a formal review if you understand our decision but disagree with it.

You can apply for a formal review at any time. You do not have to ask for an explanation first.

When you apply for a formal review, our Authorised Review Officer will:

- aim to complete the formal review within 49 days
- look at the facts, the law, and the policy involved in the decision
- change the decision if it is wrong
- write to you to let you know the outcome of your formal review.

You do not have to pay for a formal review of a decision.

## How to ask for an explanation or formal review

You can ask for an explanation or apply for a formal review using any of the following options:

- calling your regular Centrelink payment line
- calling us on **131 202** to speak with someone in your language
- visiting a service centre.

You can also fill in the *Explanation or formal review of a decision* form and give us any supporting documents online, using either:

- your Centrelink online account through myGov
- the Express Plus Centrelink mobile app.

Go to **servicesaustralia.gov.au/ss351** to download the *Explanation or formal review of a decision* form.

If you cannot give the documents to us online, you can post them to:

**Centrelink**
**Reply Paid 7800**
**Canberra BC ACT 2610**

For decisions about Assistance for Isolated Children you need to fill in a different form. This is the *ABSTUDY and Assistance for Isolated Children (AIC) Explanation or formal review of a decision form*. You can return it to us using the details on the form.

Go to **servicesaustralia.gov.au/sy054** to access the *ABSTUDY and Assistance for Isolated Children (AIC) Explanation or formal review of a decision form*.

## If you disagree with a Centrelink debt

Generally, you can ask for an explanation or apply for a formal review of your debt at any time. Some debts have different time limits for you to apply for a formal review. You can read more about time limits below.

| Payment type | Formal review time limits |
|---|---|
| Assistance for Isolated Children | You must apply for a formal review within 3 months from the date we made our decision. |
| Tertiary Access Payment | You must apply for a formal review within 13 weeks from when we tell you about the decision. |

If you have a debt, you can ask us to pause your repayments until your explanation or formal review is complete. You can do this when you talk to us about a decision.

## Time limits when applying for a formal review

You should apply for a formal review within 13 weeks from the date we tell you about the decision.

Some payments have different time limits for you to apply for a formal review. This applies to both claim and entitlement decisions.

You can still apply for a formal review after your payment review time limit. However, if the decision is changed, you may only get your payment from the date you apply for the formal review.

You can read more about time limits below.

| Payment type | Formal review time limits |
|---|---|
| Family Tax Benefit | You should apply for a formal review within 52 weeks from the date we tell you about the decision. |
| Family Tax Benefit and Child Support | You should apply for a formal review within 52 weeks from the date we tell you about the decision.<br><br>If you are also a Child Support customer and the decision affects your child support assessment, you should apply for a formal review within 28 days from the date we tell you about the decision. |
| Child Care Subsidy | You should apply for a formal review within 13 weeks from the date we tell you about the decision. |
| Parental Leave Pay | You should apply for a formal review within 28 days from the day we make the decision. |
| Dad and Partner Pay | You should apply for a formal review within 28 days from the day we make the decision. |

| | |
|---|---|
| Tertiary Access Payments | You must apply for a formal review within 13 weeks from when we tell you about the decision. |
| Assistance for Isolated Children Scheme | You can apply for a formal review at any time.<br>If the decision is about the recovery of a debt, you must apply for a formal review within 3 months from the date we made the decision. |

## If you disagree with a formal review outcome

If you disagree with a formal review outcome of a Centrelink decision, you can ask the Administrative Review Tribunal (ART) to review it. The ART is an independent tribunal.

The ART has 2 review levels. This means if you disagree with the ART's first review, you can apply for a second review.

If you are applying to the ART, you can ask us to pause your debt repayments until the ART's first review is complete.

There may be a different review and appeal process if the decision relates to the following payments:

- Assistance for Isolated Children
- Rural ex-gratia payment.

## When to apply to the ART

You should apply within 13 weeks from the date of our formal review decision. You can still apply for an ART review after 13 weeks. However, if the ART changes the decision, you may only get your payment from the date you applied for the review.

If you want a review of a Paid Parental Leave Scheme decision, you should apply within 28 days of our formal review decision.

### How to apply to the ART

To apply for an ART review of a decision, go to **art.gov.au** and follow their instructions.

After you submit an application, we will send the ART a statement. It will contain the reasons for the decision and relevant agency documents. You will also get a copy of our statement and documents.

If you disagree with the ART's first review, you may be able to apply for a second ART review. You should make an application for a second ART review within 28 days of receiving the first review decision.

### What are the costs?

For some types of decisions, there may be an ART application fee.

We cannot help you with the costs of applying for an ART review. The ART also cannot award you costs if you are successful.

If your review with the ART is unsuccessful, we do not ask you to pay our costs.

# What else you should know

## Legal assistance

You can choose to have your own legal representative if you seek a formal review of a decision.

Free advice and assistance is available from:

- Economic Justice Australia website – **ejaustralia.org.au**
- National Legal Aid website – **nationallegalaid.org**

## Compensation claims

In some cases you may be able to claim compensation if you think we have made a mistake that has caused you a financial loss or other harm.

You should explore all of your review options before you claim compensation. We may not compensate you if other options can resolve the issue.

You can claim compensation by completing the *Compensation Application* form. If you cannot print it, you can ask staff at your local service centre to print the form. You can also call us on your regular Centrelink payment line or **131 202** and we can send it to you. When calling your payment line, let us know if you need an interpreter, and we will arrange one for free.

Go to **servicesaustralia.gov.au/ss509** to download the *Compensation Application form.*

# For more information

- Go to **servicesaustralia.gov.au/reviewsandappeals** for more information in English
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language
- Call **131 202** to speak with someone in your language about Centrelink payments and services
- Call **132 011** for Medicare and **131 272** for Child Support. Let us know if you need an interpreter, and we will arrange one for free
- Visit a service centre.

Note: calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It is your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.